មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែសីហា ឆ្នាំ២០១៤

# របាយការណ៍លទ្ធផលនៃសិក្ខាសាលាស្តីពី យុវជន និងកំណែទម្រង់ការបោះឆ្នោត



**រូបគម្របមុខ ៖** ក្រុមយុវជនពិភាក្សាអំពីប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោតនៅក្នុងសិក្ខាសាលានាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩។ រូបភាពថតដោយម.ស.ម.ក © CCHR

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬ ត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តាមរយៈ ៖

ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល ៖ info@cchrcambodia.org
ទូរស័ព្ទ ៖ +៨៥៥(០)២៣ ៧២ ៦៩ ០១
គេហទំព័រ ៖ www.cchrcambodia.org

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") មិនចូលបក្សសម្ព័ន្ធ ឯករាជ្យដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ ចក្ខុវិស័យរបស់ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានមានសមភាព ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស។ ម.ស.ម.ក ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយម ដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយក និងសាទរជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ករំលេចឲ្យឃើញរូបសត្វព្រាប ស ហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

របាយការណ៍លទ្ធផលនៃសិក្ខាសាលាស្តីពី"យុវជន និងកំណែទម្រង់ការបោះឆ្នោត" គឺជាលទ្ធផលនៃគម្រោងកៀគរយុវជនជុំវិញកំណែទម្រង់ការបោះឆ្នោត("គម្រោង") របស់ម.ស.ម.ក។

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះកើតជារូបរាងឡើងបាន គឺដោយសារជំនួយរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ។ ខ្លឹមសារនៃរបាយការណ៍លទ្ធផលនេះគឺជាការទទួលខុសត្រូវរបស់ម.ស.ម.ក និងមិនឆ្លុះ

បញ្ចាំងអំពីទស្សនរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ ឡើយ។

# ខ្លឹមសារសង្ខេប

របាយការណ៍នេះសង្ខេបពីបញ្ហា និងអនុសាសន៍ដែលយុវជនបាន ពិភាក្សា និងលើកឡើងនៅក្នុងសិក្ខាសាលាស្ដីពីយុវជន និងកំណែទម្រង់ការបោះឆ្នោត” ដែលបានប្រព្រឹត្តិទៅនាថ្ងៃទី២០-២១ ខែមិថុនា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ កម្ពុជា។ សិក្ខាសាលានេះរៀបចំឡើងដោយគម្រោងកៀរគរយុវជនជុំវិញកំណែទម្រង់ការបោះឆ្នោតរបស់ម.ស.ម.ក ដែលមានគោលបំណងលើកកម្ពស់ការយល់ដឹង និងជម្រុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋ ជាពិសេស យុវជនដែលកាន់តែមានសំឡេងច្រើនក្នុងការទាមទារឲ្យមានការផ្លាស់ប្ដូរនៅក្នុងការជជែកពិភាក្សាអំពីកំណែទម្រង់ការបោះឆ្នោត ដើម្បីចូលរួមចំណែកបង្កើតអនុសាសន៍សំខាន់ៗ ដែលឆ្លុះបញ្ចាំងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

សិក្ខាសាលានេះ មានគោលបំណងផ្ដល់ឱកាសឲ្យយុវជនចូលរួមកំណត់ពីបញ្ហាព្រួយបារម្ភសំខាន់ៗដែលទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត និងបង្កើតអនុសាសន៍ ព្រមទាំងរៀនអំពីបញ្ហាសំខាន់ៗទាក់ទងការចូលរួមក្នុងវិស័យនយោបាយ និងកំណែទម្រង់ការបោះឆ្នោត។ សិក្ខាសាលានេះក៏បានផ្ដល់ឱកាសឲ្យយុវជន បង្កើនសមត្ថភាពរបស់ខ្លួននៅក្នុងការធ្វើសកម្មភាពយុទ្ធនាការ និងតស៊ូមតិ ឬកំណែទម្រង់ការបោះឆ្នោត និងបង្កើតឱកាសឲ្យយុវជនចងជាបណ្ដាញ ក្នុងចំណោមយុវជនដែលចូលរួមក្នុងសិក្ខាសាលានេះ។ នៅក្នុងសិក្ខាសាលានោះមានយុវជនចូលរួមសរុប ៤២ នាក់ ក្នុងនោះមានស្ត្រី ១៩ នាក់ ដែលមកពីក្រុមយុវជន និងស្ថាប័នផ្សេងៗគ្នា រួមមានតំណាងយុវជនមកពី សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា បណ្ដាញស្ត្រីអ្នកដឹកនាំវ័យក្មេង ក្រុមកាហ្វេនយោបាយ បណ្ដាញពង្រឹងស្ត្រី

វ័យក្មេងកម្ពុជា មូលនិធិហាប់ស្វែល ក្រុមអ្នកផ្លាស់ប្តូរ ក្រុមគម្រោងសត្វព្រៃ ក្រុមប្រឹក្សាយុវជនរបស់អគ្គរដ្ឋទូតអាមេរិក និងបណ្ដាញវិភាគ និងស្រាវជ្រាវ និងអ្នកជំនាញខាងកំណែទម្រង់ការបោះឆ្នោត ៤ រូបផ្សេងទៀត។ បន្ថែមពីនេះ មានអ្នកសារព័ត៌មាន និងបុគ្គលិករបស់ម.ស.ម.ក ។

តាមការពិភាក្សានៅក្នុងសិក្ខាសាលានេះ ក្រុមយុវជនបានកំណត់បញ្ហាគន្លឹះសំខាន់ៗទាក់ទងនឹងដំណើរការបោះឆ្នោត និងលើកឡើងនូវអនុសាសន៍ដើម្បីឆ្លើយតបទៅលើបញ្ហាទាំងអស់នោះ។ បញ្ហាទាំង៥នោះរួមមាន ១) បញ្ជីឈ្មោះបោះឆ្នោត ២) ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត ៣) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ("គ.ជ.ប") ៤) សិទ្ធិ និងសេរីភាពអ្នកបោះឆ្នោតក្នុងពេលបោះឆ្នោត និង ៥) តម្លាភាពក្នុងការបោះឆ្នោត។

# សេចក្តីផ្តើម

បន្ទាប់ពីការបោះឆ្នោតជ្រើសតំណាងរាស្ត្រនៅកម្ពុជានាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងមក លទ្ធផលផ្លូវការរបស់គ.ជ.ប បានបង្ហាញថា គណបក្សប្រជាជនកម្ពុជា ("ប្រ.ជ") ទទួលបាន ៦៨ អាសនៈ ហើយគណបក្សសង្គ្រោះជាតិ ("គ.ស.ជ") ទទួលបាន ៥៥ អាសនៈ។ ទោះបីជាលទ្ធផលយ៉ាងនេះក្តី ក៏មានការចោទប្រកាន់ជាច្រើនពីការលួចបន្លំសន្លឹកឆ្នោត និងភាពមិនប្រក្រតីជាប្រព័ន្ធកើតមានឡើងនៅក្នុងដំណើរការបោះឆ្នោត ដែលបណ្តាលឲ្យមានការទាមទារស៊ើបអង្កេតឯករាជ្យទៅលើការបោះឆ្នោតនោះ។ តំណាងរាស្ត្រ គ.ស.ជ បានបដិសេធចំពោះលទ្ធផលបោះឆ្នោតនោះ ហើយអស់រយៈកាលជិតមួយឆ្នាំមកហើយ ដែលគណបក្សនេះបានពហិការក្នុងការទទួលយកអាសនៈនៅក្នុងរដ្ឋសភា។ ក្នុងអំឡុងពេលនោះ គេសង្កេតឃើញមានមហាបាតុកម្ម និងការតវ៉ាជាច្រើនកើតឡើងដែលមានកងកម្លាំងសន្តិសុខតែងតែប្រើកម្លាំងលើសលុបក្នុងការបង្ក្រាបទៅលើការតវ៉ាទាំងនោះ ដែលនាំឲ្យមានមនុស្សយ៉ាងហោចណាស់ ៦ នាក់ស្លាប់ និងជាច្រើននាក់ទៀតរងរបួស។

ក្រោយពីការជាប់គាំងនយោបាយអស់រយៈកាលជិតមួយឆ្នាំមក ប្រ.ជ និងគ.ស.ជ បានឈានមកដល់ដំណោះស្រាយរួមគ្នាមួយបន្ទាប់ពីកិច្ចប្រជុំរវាងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និង លោកប្រធានគ.ស.ជ សម រង្ស៊ី នាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ គ.ស.ជ បានយល់ព្រមទទួលយកអាសនៈក្នុងរដ្ឋសភា ដើម្បីធ្វើការទៅលើកិច្ចការកំណែទម្រង់សំខាន់ៗមួយចំនួនដូចជា បទបញ្ជាផ្ទៃក្នុងរដ្ឋសភា កំណែទម្រង់គ.ជ.ប ជាដើម។ តាមកិច្ចព្រមព្រៀងនេះ កំណែទម្រង់ការបោះឆ្នោតគឺជាកិច្ចការអាទិភាពសម្រាប់

រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ក្នុងការដោះស្រាយបញ្ហានយោបាយថ្មីនេះ។

សិក្ខាសាលានេះបានធ្វើឡើងក្នុងរយៈពេលពីរថ្ងៃ។ ថ្ងៃទីមួយផ្តោតសំខាន់លើការពិភាក្សាអំពីបញ្ហា និងអនុសាសន៍នានាដែលក្រុមយុវជនបានលើកឡើងទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត។ មានវាគ្មិនជំនាញចំនួនបីរូបបានចូលរួមចែករំលែកទៅលើប្រធានបទផ្សេងៗគ្នាទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោតនៅកម្ពុជា រួមមាន លោកបណ្ឌិត ឡៅ ម៉ុងហៃ អ្នកវិភាគឯករាជ្យ ចែករំលែកអំពីប្រព័ន្ធបោះឆ្នោតនៅកម្ពុជា ដែលផ្តោតទៅលើតម្លាភាពនៃការបោះឆ្នោត និងគ.ជ.ប លោក ស៊ិន ទិត្យសីហា មន្ត្រីអង្កេតរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ("ខុមហ្វ្រែល") បង្ហាញអំពីការចុះឈ្មោះបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត បញ្ហាអំឡុងពេលយុទ្ធនាការបោះឆ្នោត និងអ្នកស្រី ចាន់ សោភណ្ឌ មន្ត្រីសម្របសម្រួលកម្មវិធីនៃអង្គការសីលការ លើកឡើងពីយេនឌ័រក្នុងរដ្ឋបាលបោះឆ្នោត និងតំណាងស្ត្រី។ នៅថ្ងៃទីពីរ លោក សេក បរិសុទ្ធ ជាទីប្រឹក្សាបច្ចេកទេសនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ បានបង្ហាញពីយុទ្ធសាស្ត្រតស៊ូមតិ។

យុវជនចូលរួមទាំងអស់បានរួមគ្នាកំណត់យកបញ្ហាគន្លឹះសំខាន់ៗចំនួន៥ ទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោតដើម្បីយកមកពិភាក្សា។ បញ្ហាទាំងនោះរួមមាន ១) បញ្ជីឈ្មោះបោះឆ្នោត ២) ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត ៣) គ.ជ.ប ៤) សិទ្ធិ និងសេរីភាពអ្នកបោះឆ្នោតក្នុងពេលបោះឆ្នោត និង ៥) តម្លាភាពនៃការបោះឆ្នោត។ យុវជនចូលរួមទាំងអស់ត្រូវបានបែងចែកជា ៥ ក្រុមតូចៗដែលមានមនុស្សពី ៨ ទៅ ១០ នាក់ ដើម្បីពិភាក្សាទៅលើបញ្ហាដែលបានកំណត់ខាងលើ ដោយក្នុងមួយក្រុមពិភាក្សាទៅលើ

ប្រធានមួយ។ បន្ទាប់ពីពិភាក្សាទៅលើបញ្ហានៃប្រធានបទនីមួយៗ អនុសាសន៍នានាក៏ត្រូវបានយុវជនលើកមកជជែក និង ដាក់ចេញផងដែរ។

# បញ្ហា និងអនុសាសន៍
# ទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត

## បញ្ជីឈ្មោះបោះឆ្នោត

ក្រុមយុវជនបានកំណត់យកបញ្ជីឈ្មោះបោះឆ្នោតគឺជាបញ្ហាព្រួយបារម្ភធំជាងគេដែលកើតមុនពេល និងអំឡុងពេលបោះឆ្នោត ជាពិសេសក្នុងពេលបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០១៣។ បញ្ជីឈ្មោះបោះឆ្នោតគឺជាឯកសារកត់ត្រាដ៏សំខាន់ដែលបញ្ជាក់អត្តសញ្ញាណដល់អ្នកដែលមានសិទ្ធិបោះឆ្នោតក្នុងពេលបោះឆ្នោត។ បើសិនជាប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទាំងនោះមានទិន្នន័យឈ្មោះរបស់ខ្លួនសរសេរមិនត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោត អ្នកទាំងនោះនឹងមិនអាចបោះឆ្នោតបានទេនៅថ្ងៃបោះឆ្នោត ទោះជាខ្លួនមានឯកសារបញ្ជាក់អត្តសញ្ញាណគ្រប់គ្រាន់ក៏ដោយ។

ក្រុមយុវជនបានកំណត់រកឃើញនូវបញ្ហាជាក់លាក់សំខាន់ៗមួយចំនួនដែលទាក់ទងនឹងបញ្ជីឈ្មោះបោះឆ្នោត។ បញ្ហាទី១ គឺបញ្ហារកឈ្មោះរបស់អ្នកមានសិទ្ធិបោះឆ្នោតមិនឃើញនៅក្នុងបញ្ជីនៅពេលដែលអ្នកទាំងនោះទៅបោះឆ្នោត មានន័យថាអ្នកទាំងនោះបានបាត់សិទ្ធិបោះឆ្នោត ទោះបីខ្លួនបានចុះឈ្មោះបោះឆ្នោតក្នុងពេលចុះឈ្មោះបោះឆ្នោតក៏ដោយ។ ជាងនេះទៅទៀត ក្រុមយុវជនក៏បានកត់សម្គាល់ផងដែរថាឈ្មោះរបស់អ្នកបោះឆ្នោតខ្លះត្រូវបានគេគូសនៅក្នុងបញ្ជីរួចទៅហើយ នៅពេលដែលខ្លួនទៅបោះឆ្នោត មានន័យថាអ្នកទាំងនោះមិនបានបោះឆ្នោតទេ ព្រោះមានអ្នកដទៃទៀតបានប្រើឈ្មោះខ្លួនបោះរួចទៅហើយ។

បញ្ហាផ្សេងទៀតគឺព័ត៌មានទិន្នន័យនៅក្នុងបញ្ជីឈ្មោះមិនត្រូវបានកត់ត្រាឲ្យបានច្បាស់លាស់ត្រឹមត្រូវនោះទេ ព័ត៌មានដែលខុសនោះរួមមានការសរសេរឈ្មោះខុស ខុសថ្ងៃខែឆ្នាំកំណើត ព្រមទាំងមានឈ្មោះស្ទួនជាច្រើននៅក្នុងបញ្ជីឈ្មោះ។ ឧទាហរណ៍ ឈ្មោះអ្នកបោះឆ្នោតម្នាក់អាចមាននៅក្នុងបញ្ជីការិយាល័យបោះឆ្នោតជាច្រើនកន្លែង ហើយមានឈ្មោះ និង

ព័ត៌មានខ្លះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតដែលដាក់នៅក្នុងគេហទំព័ររបស់ គ.ជ.ប ខុសពីនៅក្នុងបញ្ជីខាងក្រៅដែលបិទនៅតាមការិយាល័យបោះឆ្នោត ហើយប្រជាពលរដ្ឋមួយចំនួនមិនមានឯកសារបញ្ជាក់គ្រប់គ្រាន់ រួមមានអត្តសញ្ញាណបណ្ណ លិខិតឆ្លងដែន លិខិតបញ្ជាក់សញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត ឬ ឯកសារបញ្ជាក់ផ្សេងទៀតដើម្បីបង្ហាញដល់មន្ត្រីបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ ហេតុដូច្នេះហើយ បើទោះជាប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោត តែអ្នកទាំងនោះបានបាត់សិទ្ធិបោះឆ្នោតទៅវិញ ខណៈដែលពលរដ្ឋមួយចំនួនដែលគេចាត់ទុកជាជនជាតិវៀតណាម តែមានឯកសារគ្រប់គ្រាន់បែរជាអាចបោះឆ្នោតទៅវិញ។

ក្រុមយុវជនក៏បានជជែកបន្ថែមផងដែរ អំពីបញ្ជីឈ្មោះបោះឆ្នោតមានបញ្ហាកើតឡើងច្រើន ដោយសារទាក់ទងទៅនឹងដំណើរការចុះឈ្មោះបោះឆ្នោតដែលមានលក្ខណៈស្មុគស្មាញ។ ប្រព័ន្ធចុះឈ្មោះបោះឆ្នោតនេះត្រូវឲ្យប្រជាពលរដ្ឋចំណាយថវិកា និងពេលវេលាច្រើន។ អ្នកបោះឆ្នោតត្រូវទៅចុះឈ្មោះនៅទីតាំងលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន។ បើសិនអ្នកទាំងនោះផ្លាស់ប្តូរទីលំនៅដើម្បីទៅធ្វើការ ឬ សិក្សានៅកន្លែងណាផ្សេងទៀត អ្នកទាំងនោះត្រូវតែត្រលប់ទៅផ្ទះរបស់ខ្លួនដើម្បីចុះឈ្មោះ ឬទៅត្រួតពិនិត្យឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីដើម្បីជឿជាក់ថាឈ្មោះរបស់ខ្លួនពិតជាត្រឹមត្រូវ បើមិនដូច្នោះទេ អ្នកទាំងនោះអាចនឹងបាត់បង់សិទ្ធិបោះឆ្នោតរបស់ខ្លួនបានយ៉ាងងាយ។

## ***អនុសាសន៍***

ក្រុមយុវជនក៏បានដាក់ចេញនូវអនុសាសន៍មួយចំនួនដើម្បីឆ្លើយតបទៅនឹងបញ្ហាបញ្ជីឈ្មោះបោះឆ្នោត ៖

- គួរផ្លាស់ប្តូររដ្ឋបាល និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ជ.ប ទាក់ទិន

នឹងបញ្ជីឈ្មោះបោះឆ្នោត ដោយពង្រឹងឲ្យមានការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់មូលដ្ឋាន។

- ផ្តល់វគ្គបណ្តុះបណ្តាលដើម្បីកសាងសមត្ថភាពដល់គណៈកម្មាធិការឃុំសង្កាត់រៀបចំការបោះឆ្នោតអំពីចំណេះដឹងនូវការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងផ្តល់នូវឧបករណ៍គ្រប់គ្រាន់ដើម្បីឲ្យគណៈកម្មាធិការនេះអាចពង្រឹងការងាររបស់ខ្លួនទៅលើបញ្ជីឈ្មោះបោះឆ្នោត។
- គ.ជ.ប គួរតែរៀបចំផែនការតាមដាន និងត្រួតពិនិត្យឲ្យបានទៀងទាត់ តាមឆមាសក្តី ឬប្រចាំឆ្នាំក្តីទៅលើឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត និងចាត់វិធានការចំពោះមន្ត្រីនានាដែលមានការធ្វេសប្រហែសក្នុងការធ្វើការទៅលើបញ្ជីឈ្មោះ ជាជាងមិនអើពើចំពោះបញ្ហានេះ។
- គួរធានាថាព័ត៌មានបញ្ជីឈ្មោះបោះឆ្នោតត្រូវតែផ្សព្វផ្សាយឲ្យបានទូលំទូលាយទូទាំងប្រទេសបន្ថែមទៀត ជាពិសេសនៅតំបន់ដាច់ស្រយាល ដើម្បីឲ្យប្រជាពលរដ្ឋអាចទទួលព័ត៌មានបាន ហើយត្រូវតែផ្សព្វផ្សាយព័ត៌មានទាំងនេះជាភាសាជនជាតិដើមភាគតិចផងដែរដើម្បីឲ្យជនជាតិដើមភាគតិចអាចទទួលព័ត៌មាននេះបាន។
- គួរទម្លាក់កញ្ចប់ថវិកាឲ្យបានគ្រប់គ្រាន់ទៅគណៈកម្មាធិការនៅថ្នាក់មូលដ្ឋានដើម្បីធ្វើការទៅលើការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត។
- គ.ជ.ប គួរធ្វើការសម្របសម្រួល និងគ្រប់គ្រងដំណើរការចុះឈ្មោះបោះឆ្នោតនៅថ្នាក់មូលដ្ឋាន និង
- បង្កើតក្រុមពិសេសដើម្បីធ្វើការទៅលើការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋដែលបានចំណាកស្រុកទៅធ្វើការនៅបរទេស ជន

ពិការ និងអ្នកជំងឺ ជាដើម។

## ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត

តួនាទីប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោតគឺជាបញ្ហាសំខាន់ផ្សេងទៀតដែលយុវជនចូលរួមបានលើកឡើង។ ក្រុមយុវជនបានរកឃើញថាមានបញ្ហាមួយចំនួនដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ។ បញ្ហាមួយដ៏សំខាន់ក្នុងចំណោមបញ្ហាទាំងនោះគឺបញ្ហាគ.ជ.ប ដែលមិនបានផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយទៅកាន់សាធារណ:ជនទូទាំងប្រទេសទាក់ទងនឹងដំណើរការបោះឆ្នោត រួមទាំងការចុះបញ្ជីឈ្មោះបោះឆ្នោត ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត លទ្ធផលបោះឆ្នោត កម្មវិធីនយោបាយ ។ល។ រឿងទាំងអស់នេះកើតឡើងជាពិសេសនៅតំបន់ដាច់ស្រយាល ដែលប្រជាពលរដ្ឋកម្រនឹងទទួលបានព័ត៌មានអំពីការបោះឆ្នោត។

ក្រុមយុវជនក៏បានកត់សម្គាល់ផងដែរថាប្រព័ន្ធផ្សព្វផ្សាយស្ទើរតែទាំងអស់ស្ថិតក្រោមការគ្រប់គ្រងរបស់គណបក្សកាន់អំណាច ហើយគាំទ្រដល់រដ្ឋាភិបាលកាន់អំណាចផងដែរ។ ដូចនេះហើយ អំឡុងពេលយុទ្ធនាការបោះឆ្នោត ស្ថានីយផ្សព្វផ្សាយភាគច្រើនពេញចិត្តលក់ម៉ោងផ្សាយរបស់ខ្លួនទៅឲ្យតែគណបក្សកាន់អំណាចប្រ.ជ ដោយអះអាងថាមិនមានម៉ោងទំនេរលក់ទៅឲ្យគណបក្សដទៃទៀតនោះទេ។ ទោះបី គ.ជ.ប បានចេញជាបទបញ្ញត្តិស្តីពីការផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងការលក់ម៉ោងផ្សាយរបស់ខ្លួនឲ្យបានស្មើគ្នាទៅឲ្យគណបក្សនយោបាយអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតក៏ដោយ។ ជាងនេះទៅទៀត ទោះបីមានស្ថានីយទូរទស្សន៍មួយចំនួនបានផ្សព្វផ្សាយព័ត៌មានស្មើគ្នាទៅឲ្យគ្រប់គណបក្សនយោបាយទាំងអស់ ជាពិសេសគណបក្សប្រឆាំងក៏ដោយ ក៏ព័ត៌មានឬ ដំណឹងរបស់គណបក្សទាំងនោះត្រូវបានផ្សាយ និងបកស្រាយខុសពីព័ត៌មានជាក់ស្តែង

ទៅវិញ។ អ្នករាយការណ៍ព័ត៌មានទាំងនោះហាក់ដូចជាមិនប្រកាន់វិជ្ជាជីវៈការងាររបស់ខ្លួន និងមានភាពលំអៀង។ ការប្រើប្រាស់ពាក្យពេចន៍ និងភាសានៅក្នុងប្រព័ន្ធផ្សព្វផ្សាយនោះក៏មិនសមរម្យ និងអសុរសចំពោះគណបក្សនយោបាយដទៃទៀតផងដែរ។ ក្រុមយុវជនក៏កត់សម្គាល់ផងដែរថា ទោះបីជា គ.ជ.បចេញផ្សាយព័ត៌មានពីការបោះឆ្នោតនៅលើគេហទំព័ររបស់ខ្លួនក៏ដោយ ក៏ព័ត៌មាននោះពិបាកបើកមើល និងប្រើប្រាស់ ជាពិសេសនៅថ្ងៃបោះឆ្នោត ប្រព័ន្ធទិន្នន័យបញ្ជីឈ្មោះបោះឆ្នោតត្រូវបានបិទ ដោយមិនបានបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់។

ក្រុមយុវជនក៏លើកឡើងពីជនជាតិដើមភាគតិចដែលរស់នៅទូទាំងខេត្ត ១៥ ជុំវិញប្រទេស អាចទទួលព័ត៌មានបានតាមរយៈតែវិទ្យុដែលស្ថានីយភាគច្រើនផ្សាយជាភាសាខ្មែរ ដូចនេះជនជាតិដើមភាគតិចទាំងនោះមិនអាចយល់ច្បាស់ពីព័ត៌មាននោះបានទេ។ ជាចុងក្រោយ ក្រុមយុវជនក៏បានកត់សម្គាល់ថាស្ថានីយវិទ្យុជាខេមរភាសាមួយចំនួនដែលមានមូលដ្ឋាននៅក្រៅប្រទេស (ដូចជា វិទ្យុអាស៊ីសេរី សម្លេងសហរដ្ឋអាមេរិក និងវិទ្យុបារាំងអន្តរជាតិ) ដែលគេជឿថាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ មិនត្រូវក្រសួងព័ត៌មានអនុញ្ញាតឲ្យផ្សាយបន្តតាមវិទ្យុក្នុងស្រុកនៅមុនថ្ងៃបោះឆ្នោតមួយថ្ងៃ និងថ្ងៃបោះឆ្នោត ដោយមិនបានបញ្ជាក់មូលហេតុច្បាស់លាស់។ នេះជាបញ្ហាសំខាន់ណាស់ ព្រោះវិទ្យុទាំងនេះបានផ្តល់ព័ត៌មានជាក់លាក់ពីបញ្ហាបោះឆ្នោត ហើយប្រជាពលរដ្ឋខ្មែរភាគច្រើនចូលចិត្តតាមដានស្តាប់ព័ត៌មានវិទ្យុទាំងនេះ ដោយសារតែមហាជនភាគច្រើនជឿជាក់ថាព័ត៌មានផ្សព្វផ្សាយតាមទូរទស្សន៍សុទ្ធតែគាំទ្រគណបក្សកាន់អំណាច។

### អនុសាសន៍

ក្រុមយុវជនក៏បានដាក់ចេញនូវអនុសាសន៍មួយចំនួនដើម្បីឆ្លើយតប

ទៅនឹងតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលបោះឆ្នោត ៖

- ព័ត៌មានទាក់ទងនឹងការបោះឆ្នោត ជាពិសេសការចុះបញ្ជីឈ្មោះបោះឆ្នោត និងលទ្ធផលបោះឆ្នោតត្រូវតែផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមប្រព័ន្ធផ្សព្វផ្សាយ អ៊ិនធឺណែត និងមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀតដែលអាចធ្វើទៅបាន ជាពិសេសព័ត៌មាននេះត្រូវតែផ្សព្វផ្សាយឲ្យដល់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល។
- គ.ជ.ប និងអាជ្ញាធរតាមមូលដ្ឋានត្រូវធ្វើការរួមគ្នាដើម្បីផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយ តាមមធ្យោបាយនានាដែលអាចធ្វើទៅបាន ដូចជាតាមរយៈការប្រជុំ ការចាក់ផ្សាយតាមភូមិ និងចុះជួបផ្ទាល់ពន្យល់ដល់ប្រជាពលរដ្ឋ។
- ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវផ្សាយទៅតាមបទបញ្ញត្តិរបស់ គ.ជ.ប ក្នុងការផ្សព្វផ្សាយព័ត៌មានអំឡុងពេលយុទ្ធនាការបោះឆ្នោត ហើយអ្នកយកព័ត៌មានត្រូវប្រកាន់ខ្ជាប់វិជ្ជាជីវៈជាអ្នកសារព័ត៌មាន និង
- ក្រសួងព័ត៌មានត្រូវបង្កលក្ខណៈយ៉ាងណាឲ្យប្រជាពលរដ្ឋអាចទទួលបានព័ត៌មានអំពីការបោះឆ្នោតដោយសេរី តាមរយៈប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ នៅមុន អំឡុង និងក្រោយការបោះឆ្នោត។

## កង្វះឯករាជ្យភាពរបស់ គ.ជ.ប

ក្រុមយុវជនដែលបានពិភាក្សាពី គ.ជ.ប បានកត់សម្គាល់ផងដែរ ស្ថាប័ននេះដើរតួយ៉ាងសំខាន់ក្នុងការរៀបចំ និងគ្រប់គ្រងការបោះឆ្នោតនៅកម្ពុជា។ ប៉ុន្តែ លទ្ធផលបោះឆ្នោត ៥ លើកតាំងពីឆ្នាំ១៩៩៣ កន្លងមកតែងបន្សល់នូវទំនាស់បោះឆ្នោត ដោយសារការបន្លំសន្លឹកឆ្នោត និងភាពមិនប្រក្រតីក្នុងពេលបោះឆ្នោត។ គណបក្សនយោបាយ និងប្រជាពលរដ្ឋភាគច្រើនមិនមានទំនុកចិត្តទៅលើ គ.ជ.ប នោះទេ ហើយតែងចាត់ទុកស្ថាប័ននេះមិនឯករាជ្យ។ ក្រុមយុវជនបានពិភាក្សាបញ្ហាមួយចំនួនទាក់ទិននឹងកង្វះឯករាជ្យរបស់ គ.ជ.ប ដោយសមាជិកភាគច្រើនរបស់ គ.ជ.ប មកពីគណបក្សកាន់អំណាច ហើយបំរើការដើម្បីតែប្រយោជន៍របស់គណបក្សខ្លួន ជាងប្រយោជន៍ជាតិ។ ក្រុមយុវជនក៏កត់សម្គាល់ផងដែរថាតាំងពីឆ្នាំ១៩៩៣ មកលទ្ធផលបោះឆ្នោតតែងមានលទ្ធផលដដែលៗ ដោយសារមានតែ ប្រ.ជ បានឈ្នះឆ្នោត ហើយបានបន្តគ្រប់គ្រងរដ្ឋាភិបាលរហូត។

ក្រុមយុវជនក៏កត់សម្គាល់ថាសមត្ថភាព និងចំណេះដឹងរបស់បុគ្គលិករបស់គ.ជ.ប នៅតែមានកម្រិត ជាពិសេសអ្នកដែលធ្វើការនៅតាមខេត្ត។ មន្ត្រីខ្លះមិនបានបំពេញការងាររបស់ខ្លួនឲ្យបានល្អនោះទេ ឧទាហរណ៍ដូចជា បន្ទាប់ពីបោះឆ្នោតរួច សន្លឹកឆ្នោតទាំងអស់ត្រូវតែរក្សាទុកក្នុងកញ្ចប់សុវត្ថិភាពបិទជិត ប៉ុន្តែកញ្ចប់ខ្លះនៅតាមការិយាល័យបោះឆ្នោតមួយចំនួនបែរជាមិនបានបិទជិតឲ្យបានត្រឹមត្រូវនោះទេ ។ ជាងនេះទៅទៀត មន្ត្រីខ្លះនៅតាមការិយាល័យបោះឆ្នោតនៅតំបន់ដាច់ស្រយាលមិនបានគោរពតាមគោលការណ៍ណែនាំក្នុងដំណើរការការិយាល័យបោះឆ្នោតនោះទេ ដោយការិយាល័យខ្លះបើកយឺតក្រោយម៉ោងកំណត់ ហើយបិទលឿនមុនម៉ោង

កំណត់។

ក្រុមយុវជនបានពិភាក្សាទៅលើយន្តការដោះស្រាយបណ្តឹងរបស់ គ.ជ.ប ដែលមានមានលក្ខណៈលំអៀង និងមិនមានប្រសិទ្ធិភាព។ ឧទាហរណ៍ ក្នុងចំណោមបណ្តឹង ២៥០ ដែល គ.ជ.បទទួលបាន មានតែ ១៩ បណ្តឹងធំៗប៉ុណ្ណោះដែលបានដោះស្រាយ រីឯបណ្តឹងផ្សេងៗទៀតមិនបានដោះស្រាយនោះទេ។ បណ្តឹង ៨ ករណីរបស់គណបក្សប្រឆាំងមិនត្រូវបានដោះស្រាយនោះទេ។ នៅថ្ងៃបោះឆ្នោត មានប្រជាពលរដ្ឋមួយចំនួនទទួលរងការគំរាមគំហែងពីសំណាក់គណបក្សនយោបាយ ប៉ុន្តែ គ.ជ.ប មិនបានចាត់វិធានការដោះ ស្រាយបញ្ហានោះទេ។ បញ្ហាផ្សេងទៀតគឺទាក់ទងនឹងទឹកថ្នាំជ្រលក់ដៃដែលមានគុណភាពអន់ ដោយសារតែទឹកថ្នាំនេះអាចត្រូវលាងជ្រះ ដែលនាំឲ្យមានពាក្យចរចារមារាមថាប្រជាពលរដ្ឋម្នាក់អាចបោះឆ្នោតបានច្រើនដង។ គ.ជ.ប មិនបានប្រើប្រាស់ម៉ោងផ្សាយចំពេលដែលប្រជាពលរដ្ឋមើលច្រើនចាក់ផ្សាយពីកម្មវិធីអប់រំស្តីពីការបោះឆ្នោតនោះទេ កម្មវិធីអប់រំទាក់ទិននឹងការបោះឆ្នោត និងកម្មវិធីនយោបាយច្រើនចាក់ផ្សាយនៅពេលយប់ជ្រៅ ដូចនេះទើបមានអ្នកចូលមើលកម្មវិធីនេះតិចតួច។

## ***អនុសាសន៍***

ក្រុមយុវជនក៏បានដាក់ចេញនូវអនុសាសន៍មួយចំនួនដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះឯករាជ្យភាពរបស់គ.ជ.ប ៖

- មានការជជែកពិភាក្សាថាតើសមាជិករបស់គ.ជ.ប គួរតែជាសមាជិកមកពីគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា ឬ ជាអ្នកមិនពាក់ព័ន្ធនឹងគណបក្សនយោបាយសោះ ព្រោះវាជាស្ថាប័នឯករាជ្យ។ អ្នកចូលរួមមួយចំនួនលើកឡើងថា បើសិនជាសមាជិករបស់គ.ជ.ប មកពីគណបក្សនយោបាយ អ្នកទាំងនោះត្រូវតែជ្រើស

ចេញពីគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាស្មើគ្នាព្រមទាំង មានសមាជិកមកពីស្ថាប័នសង្គមស៊ីវិលផងដែរ។

- អាណត្តិរបស់ប្រធានគ.ជ.ប គួរតែត្រូវបានកំណត់រយៈពេលឲ្យបានច្បាស់លាស់។
- សមាជិករបស់គ.ជ.ប គួរត្រូវជ្រើសរើសដោយប្រកួតប្រជែងគ្នាតាមជំនាញ និងចំណេះដឹង ហើយគួរតែធ្វើការជិតដិតដើម្បីឃ្លាំមើល និងគ្រប់គ្រងដំណើរការបោះឆ្នោតនៅកម្ពុជា និងមានទំនួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់ ។
- បុគ្គលិករបស់គ.ជ.ប នៅថ្នាក់ក្រោមជាតិ មិនត្រូវជាមន្ត្រីអាជ្ញាធរមូលដ្ឋាននោះទេ។ មន្ត្រីទាំងនោះត្រូវតែឆ្លងកាត់ការជ្រើសរើសដោយផ្ទាល់ពី គ.ជ.ប និងពឹងផ្អែកទៅលើសមត្ថភាពរបស់ខ្លួន។ ការិយាល័យរបស់គណៈកម្មាធិការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោមជាតិគួរបែកចេញពីការិយាល័យរបស់ឃុំសង្កាត់ ស្រុក និងខេត្ត។
- គ.ជ.ប ត្រូវតែជាស្ថាប័នឯករាជ្យដែលមិនស្ថិតនៅក្រោមស្ថាប័នអង្គនីតិប្រតិបត្តិណាមួយនោះទេ (មិនដូចបច្ចុប្បន្ននេះគ.ជ.ប គឺស្ថិតនៅក្រោមក្រសួងមហាផ្ទៃ។)
- គ.ជ.ប គួរតែបង្កើតកម្មវិធីអប់រំការបោះឆ្នោត និងផ្សព្វផ្សាយឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីលើកទឹកចិត្តឲ្យប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់នៃការបោះឆ្នោត ការផ្សព្វផ្សាយគួរតែជ្រើសរើសពេលវេលាណាដែលអាចឲ្យប្រជាពលរដ្ឋភាគច្រើនទទួលបានព័ត៌មាននោះ។

- គួរសើរើរចនាសម្ព័ន្ធដំណើរការនៃការចុះបញ្ជីឈ្មោះបោះឆ្នោត គួរបង្កើតក្រុមពិសេសដើម្បីធ្វើការទៅលើការចុះឈ្មោះបោះឆ្នោតទៅដល់ក្រុមងាយរងគ្រោះ ដូចជា ជនពិការ អ្នកជំងឺរ៉ាំរ៉ៃ ជនជាតិដើមភាគតិច កម្មករចំណាកស្រុក ហើយរដ្ឋបាលបោះឆ្នោតនៅថ្នាក់មូលដ្ឋានគួរតែបានបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីងាយស្រួលក្នុងការចុះបញ្ជីឈ្មោះបោះឆ្នោត និង
- តំណាងគណបក្សនយោបាយ និងសង្គមស៊ីវិលគួរដាក់អ្នកសង្កេតការណ៍តាមដានរាល់សម្ភារៈសម្រាប់ការបោះឆ្នោតទាំងអស់ រួមទាំងថ្នាំជ្រលក់ និងសន្លឹកឆ្នោតផងដែរ។

## សិទ្ធិ និងសេរីភាពក្នុងពេលបោះឆ្នោត

អ្នកចូលរួមបានលើកឡើងអំពីសិទ្ធិ និងសេរីភាពក្នុងពេលបោះឆ្នោត គឺជាញ្ហាសំខាន់មួយទៀតសម្រាប់កំណែទម្រង់ការបោះឆ្នោត។ បន្ទាប់ពីការជជែកពិភាក្សា ក្រុមយុវជនបានកំណត់បញ្ហាមួយចំនួនទាក់ទងនឹងប្រធានបទនេះ ដូចជា ជាក់ស្តែងប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ពីសិទ្ធិបោះឆ្នោតរបស់ខ្លួនដែលត្រូវបានធានាដោយច្បាប់ជាតិ និងអន្តរជាតិ ដូច្នេះហើយ ជនងាយរងគ្រោះភាគច្រើន តែងរងការគំរាមកំហែងពីគណបក្សនយោបាយ។ ក្រុមយុវជនក៏បានពិភាក្សាផងដែរអំពីសិទ្ធិបោះឆ្នោតដែលអាចត្រូវរំលោភបំពាននៅក្នុងគ្រួសារ និងសហគមន៍ខ្លួនផងដែរ ប្រសិនបើសមាជិកក្រុមគ្រួសារនោះមាននិន្នាការនយោបាយខុសគ្នា ដែលបញ្ហានេះអាចនាំឲ្យមានជម្លោះ និងការរើសអើងរវាងគ្នានិងគ្នា ដោយសារតែទស្សនៈនយោបាយផ្សេងពីគ្នា។

ទាក់ទងនឹងអ្នករស់នៅបរទេស ក្រុមពិភាក្សាបានកត់សម្គាល់ឃើញថា ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រៅប្រទេសបានបាត់បង់សិទ្ធិបោះឆ្នោតរបស់ខ្លួន ព្រោះអ្នកទាំងនោះគ្មានមធ្យោបាយណាមួយដែលខ្លួនអាចបោះឆ្នោតបាន នៅពេលដែលរស់នៅក្រៅប្រទេស។ ក្រុមក៏បានកត់សម្គាល់ផងដែរថា អាជ្ញាធរមូលដ្ឋានបានចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត តែងរើសអើងចំពោះសកម្មជន និងគណបក្សប្រឆាំង។ ជាងនេះទៀត ការចែកអំណោយ ឬរបស់របររបស់គណបក្សនយោបាយ ត្រូវបានលើកឡើងថាជាវិធីសាស្ត្រសម្រាប់ទិញសន្លឹកឆ្នោតដែលគណបក្សនយោបាយចូលចិត្តប្រើប្រាស់ក្នុងពេលបោះឆ្នោត។ ទោះបីជាប្រជាពលរដ្ឋខ្លះសប្បាយចិត្តក្នុងការទទួលយកអំណោយដែលគេផ្តល់ឲ្យក៏ដោយ ក៏

ប្រជាពលរដ្ឋទាំងនោះមានអារម្មណ៍ថាខ្លួនត្រូវតែបោះឆ្នោតទៅឲ្យគណបក្សនយោបាយនោះផងដែរ ដោយសារតែខ្លួនបានទទួលអំណោយពីគណបក្សនយោបាយនោះ។

ចុងក្រោយ ក្រុមបានពិភាក្សាទៅលើបញ្ហាមួយចំនួន ដូចជាព័ត៌មានបញ្ជីឈ្មោះបោះឆ្នោតខុស (រួមមានខុសឈ្មោះ ខុសថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងអាស័យដ្ឋានអចិន្ត្រៃយ៍។ល។) មានន័យថាអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបាន ដោយសារតែព័ត៌មានខុសពីឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតនីមួយៗ ជាក់ស្តែងអ្នកបោះឆ្នោតមិនមានឯកសារគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីព័ត៌មានខ្លួនឯង និងទីតាំងនៃការិយាល័យបោះឆ្នោតត្រូវបានផ្លាស់ប្តូរនៅនាទីចុងក្រោយ ដោយសារហេតុផលសុវត្ថិភាព ហើយប្រជាពលរដ្ឋមិនបានទទួលព័ត៌មានពេញលេញអំពីការផ្លាស់ប្តូរទីតាំងនោះ។

### ***អនុសាសន៍***

- គួរមានបទបញ្ញាណាមួយដើម្បីហាមគណបក្សនយោបាយទាំងអស់ក្នុងការចែកអំណោយ របស់របរ ឬការបរិច្ចាកទៅឲ្យប្រជាពលរដ្ឋអំឡុងពេលបោះឆ្នោត ជាពិសេសអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត។
- រដ្ឋាភិបាលគួរបញ្ចូល ឬ បញ្ជ្រាបចំណេះដឹងទាក់ទងនឹងការបោះឆ្នោត និងសិទ្ធិចូលរួមក្នុងនយោបាយទៅក្នុងកម្មវិធីសិក្សាផ្លូវការដោយចាប់ផ្តើមពីអនុវិទ្យាល័យឡើងទៅ។
- គ.ជ.ប គួរបង្កើនកម្មវិធីអប់រំ និងបណ្តុះបណ្តាលទៅលើសិទ្ធិ និងសេរីភាពអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតនៅតាមសហគមន៍ដាច់ស្រយាល ដែលការយល់ដឹង និងចំណេះដឹងរបស់ពួកគាត់នៅមាន

កម្រិតនៅឡើយ។

- ពង្រឹងច្បាប់ និងដាក់ទោសទណ្ឌទៅលើជនណាដែលរំលោភសិទ្ធិ និងសេរីភាពក្នុងការបោះឆ្នោត។
- ធានាថាប្រជាពលរដ្ឋកម្ពុជាដែលរស់នៅ ឬធ្វើការក្រៅប្រទេសមានសិទ្ធិបោះឆ្នោត មាត្រា៥០នៃច្បាប់ស្តីពីការបោះឆ្នោតគួរធ្វើវិសោធនកម្ម និង
- រដ្ឋាភិបាលគួររកវិធីសាស្ត្រផ្សេងៗដើម្បីសម្របសម្រួលឲ្យប្រជាពលរដ្ឋអាចបោះឆ្នោតបាន ឧទាហរណ៍តាមរយៈការបង្កើតការិយាល័យបោះឆ្នោតនៅតាមស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជានៅក្រៅប្រទេស ដូច្នេះប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រៅប្រទេសទាំងនោះអាចប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួនបាន។

## តម្លាភាពក្នុងការបោះឆ្នោត

តម្លាភាពក្នុងការបោះឆ្នោតគឺជាបញ្ហាសំខាន់មួយទៀតដែលអ្នកចូលរួមបានកំណត់លើកឡើង។ បន្ទាប់ពីការពិភាក្សាដ៏ស៊ិតស្វាញ ចំនុចមួយចំនួនត្រូវបានលើកឡើងជាក់ស្តែងរួមមាន ទោះបីជាទិន្នន័យបញ្ជីឈ្មោះអ្នកបោះឆ្នោតបានដាក់ផ្សាយជាសាធារណៈនៅលើអ៊ិនធឺណែតក្តី ភាគច្រើនគេហទំព័រនោះតែងមានបញ្ហាបច្ចេកទេស ជាងនេះទៀតទិន្នន័យបញ្ជីឈ្មោះនោះត្រូវបានបិទនៅមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោតតែម្តង។ មួយវិញទៀត លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតត្រូវបានចេញឲ្យអ្នកដែលមិនមានឯកសារបញ្ជាក់គ្រប់គ្រាន់។ លក្ខខណ្ឌក្នុងការស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតនេះគឺត្រូវមានសាក្សីយ៉ាងហោចណាស់ពីរនាក់ដែលរស់នៅក្នុងឃុំរបស់ខ្លួន។ ដំណើរការក្នុងការចេញលិខិតបញ្ជាក់នេះមិនមានតម្លាភាព និងដូចបានបង្ហាញខាងដើមសកម្មជន និងគណបក្សប្រឆាំងត្រូវបានរើសអើងនៅក្នុងដំណើរការការងារនេះ។

ក្រុមក៏បានពិភាក្សាផងដែរអំពីការិយាល័យបោះឆ្នោតមួយចំនួនដែលបានបិទទ្វារ នៅពេលដែលមន្ត្រីបោះឆ្នោតកំពុងរាប់ស្លឹកឆ្នោតនៅក្នុងការិយាល័យទាំងនោះ។ ម្យ៉ាងវិញទៀត គេឃើញមានភាពមិនប្រក្រតីនៅពេលដែលប្រកាសលទ្ធផលបណ្តោះអាសន្ននៅតាមទូរទស្សន៍ និងវិទ្យុជាតិគឺក្រោយពេលប្រកាសលទ្ធផលបានរយៈពេលមួយម៉ោង ភ្លាមនោះការប្រកាសលទ្ធផលក៏ត្រូវបានបញ្ឈប់ដោយមិនបញ្ជាក់ពីមូលហេតុ។ បញ្ហានេះបានធ្វើឲ្យទស្សនិកជន និងអ្នកស្តាប់សង្ស័យ និងងឿងឆ្ងល់ជាច្រើនទៅលើបញ្ហានេះ។ នៅចុងបញ្ចប់ ក្រុមបានកត់សម្គាល់ឃើញថាប្រព័ន្ធផ្សព្វផ្សាយ

ភាគច្រើន ជាពិសេសទូរទស្សន៍ជាតិ និងវិទ្យុជាតិមិនបានផ្តល់ព័ត៌មានដែលមានតម្លាភាព និងឯករាជ្យទាក់ទងនឹងការបោះឆ្នោតនោះទេ។ គណបក្សកាន់អំណាចទទួលបានម៉ោងចាក់ផ្សាយច្រើនជាងគេ ខណៈដែលគណបក្សតូចជាង និងគណបក្សប្រឆាំងមិនសូវត្រូវបានចាក់ផ្សាយនោះទេ។

## *អនុសាសន៍*

អនុសាសន៍ខាងក្រោមនេះត្រូវបានស្នើឡើងដោយក្រុមដើម្បីឆ្លើយតបទៅនឹងបញ្ហាតម្លាភាពក្នុងការបោះឆ្នោត ៖

- គ.ជ.ប គួរធានាថាព័ត៌មានសំខាន់អំពីការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈតាមមធ្យោបាយផ្សេងៗ រួមទាំងការផ្សាយតាមឯកសារបោះពុម្ពផ្សាយ និងតាមរយៈអ៊ីនធឺណែត ព្រមទាំងការជួបប្រជុំផ្ទាល់នៅក្នុងសហគមន៍។
- គ.ជ.ប គួរធានាថាទ្វារការិយាល័យបោះឆ្នោតបើកនៅពេលដែលកំពុងរាប់សន្លឹកឆ្នោត និងធានាថាលទ្ធបោះឆ្នោតបណ្តោះអាសន្នត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសតាមរយៈទូរទស្សន៍ជាតិ និងវិទ្យុជាតិ ដោយគ្មានការរឹតត្បិតព័ត៌មាន និង
- ព័ត៌មានទាក់ទងនឹងដំណើរការបោះឆ្នោតមិនគួរមានតែជាភាសាខ្មែរប៉ុណ្ណោះទេ តែមានជាភាសាជនជាតិដើមភាគតិចផងដែរ។

# សេចក្តីសន្និដ្ឋាន

ប្រធានបទដែលអ្នកចូលរួមនៅក្នុងសិក្ខាសាលាបានលើកឡើង បានរំលេចឡើងនូវបញ្ហាជាច្រើន ដែលបន្តរាំងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យរបស់កម្ពុជា និងចូលរួមរំលោភសិទ្ធិក្នុងការចូលរួមក្នុងជីវិតនយោបាយ ដែលត្រូវបានការពារនៅក្រោមច្បាប់ជាតិ និងអន្តរជាតិ។ ការពិភាក្សាទៅលើប្រធានបទសំខាន់ៗទាំងនេះដែលសង្ខេបនៅក្នុងរបាយការណ៍លទ្ធផលនេះ បង្ហាញឲ្យឃើញថាកំណែទម្រង់ការបោះឆ្នោតគឺជាបញ្ហាមួយដែលទាក់ទងនឹងយុវជនកម្ពុជា ដែលមានការចូលរួមកាន់តែច្រើនក្នុងការផ្លាស់ប្តូរលទ្ធិប្រជាធិបតេយ្យរបស់កម្ពុជា។ យើងសង្ឃឹមថា សិក្ខាលា និងរបាយការណ៍លទ្ធផលនេះនឹងជួយឲ្យមានសំឡេងរបស់យុវជន។ អនុសាសន៍ដែលយុវជនចូលរួមបានស្នើឡើង ហើយមានសរសេរនៅក្នុងរបាយណ៍លទ្ធផលនេះ ផ្តល់ជាជំហានជាក់លាក់សម្រាប់រដ្ឋាភិបាល គណបក្សនយោបាយ និងគ.ជ.ប យកទៅអនុវត្តនៅក្នុងដំណើរការកំណែទម្រង់ការបោះឆ្នោត។

# ឧបសម្ព័ន្ធ

ក្រុមយុវជន និងស្ថាប័នដែលបានចូលរួមសិក្ខាសាលា ៖

*ក្រុមយុវជន៖*

- បណ្តាញពង្រឹងសិទ្ធិអំណាចស្ត្រីវ័យក្មេងនៅកម្ពុជា
- ក្រុមអ្នកផ្លាស់ប្តូរ (Chang Maker)
- ក្រុមខ្មែរជួយខ្មែរ
- ក្រុមការហ្វេនយោបាយ
- គម្រោងជីវិតសត្វព្រៃ
- បណ្តាញស្ត្រីអ្នកដឹកនាំវ័យក្មេង
- បណ្តាញស្ត្រីវ័យក្មេង

*សាកលវិទ្យាល័យ*

- សាកលវិទ្យាល័យខេមរៈ
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- សាកលវិទ្យាល័យកម្ពុជា
- អ្នកវិភាគឯករាជ្យ

*អង្គការមិនមែនរដ្ឋាភិបាល*

- វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
- សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា
- គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា
- មូលនិធិហាប់ស្វៃល

- សមាគមយុវជនខ្មែរ
- វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ
- អង្គការសីលការ
- អង្គការតម្លាភាពកម្ពុជា
- អង្គការយុវជន និងកុមារដើម្បីសេរីភាព
- ក្រុមប្រឹក្សាយុវជនកម្ពុជា
- អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន